Minnesota Department of Health

# ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

ប្រែសម្រួលសម្រាប់ SLFS ពីលក្ខន្តិកៈ រដ្ឋMINNESOTA 144.651ច្បាប់សិទ្ធិមូលដ្ឋានស្តីពីការថែទាំសុខភាព

## គោលបំណងនីតិបញ្ញត្តិ

គោលបំណងនៃអង្គនីតិបញ្ញត្តិនិងគោលបំណងនៃផ្នែកនេះ
គឺដើម្បីលើកកម្ពស់ផលប្រយោជន៍និងសុខុមាលភាពរបស់និវាសនជនរស់នៅមណ្ឌលសេវាថែទាំសុខភាព ។មណ្ឌលសេវាថែទាំសុខភាព
មិនតម្រូវឱ្យនិវាសនជនលះបង់សិទ្ធិទាំងនេះជាលក្ខខណ្ឌនៃការអនុញ្ញាតចូលមណ្ឌលនេះទេ។អា

# ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

ណាព្យាបាលឬអ្នកអភិរក្សណាមួយរបស់និវាសនជនឬអវត្តមានអាណាព្យាបាលឬអ្នកអភិរក្សសាមីខ្លួនអាចស្វែងរកការអនុវត្តសិទ្ធិទាំងនេះក្នុងនាមជានិវាសនជនម្នាក់។សាមីខ្លួនអាចស្វែងរកការអនុវត្តសិទ្ធិទាំងនេះក្នុងនាមជានិវាសនជនដែលមានអាណាព្យាបាលឬអ្នកអភិរក្សតាមរយៈទីភ្នាក់ងាររដ្ឋបាល ឬតុលាការមណ្ឌលដែលមានដែនសមត្ថកិច្ចលើអាណាព្យាបាលនិងអ្នកអភិរក្ស។ដោយរង់ចាំលទ្ធផលនៃការអនុវត្តបន្តមណ្ឌលសេវាថែទាំ ឬមន្ទីរសេវាថែទាំអាចគោរពតាមការណែនាំរបស់អាណាព្យាបាលឬអ្នកអភិរក្សដោយសុទ្ធចិត្ត។គោលបំណងនៃច្បាប់នេះថែងថាសេរីភាពស៊ីវិលនិងសាសនារបស់និវាសនជនដោយរួមបញ្ចូលទាំងសិទ្ធិក្នុងការសម្រេចចិត្តផ្ទាល់ខ្លួនដោយឯករាជ្យនិងចំណេះដឹងអំពីជម្រើសដែលមានមិនត្រូវបានបំពាន ហើយមណ្ឌលសេវាថែទាំ ឬមន្ទីរសេវាថែទាំត្រូវលើកទឹកចិត្តនិងជួយអនុវ

ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

ក្តសិទ្ធិទាំងនេះឲ្យបានពេញលេញដតាមដែលអាចធ្វើទៅបាន។

# និយមន័យ

ចំពោះគោលបំណងនៃសេចក្តីថ្លែងការណ៍នេះ "និវាសនជន" មានន័យថាបុគ្គលម្នាក់ដែលត្រូវបានអនុញ្ញាតចូលមណ្ឌលដែលមានអាជ្ញាប័ណ្ណដែលជាមណ្ឌលរស់នៅក្រោមការគ្រប់គ្រងក្រោមវិធានរដ្ឋMinnesotaផ្នែក 4665.0100ដល់4665.9900។

# សេចក្តីថ្លែងការណ៍ពីគោលនយោបាយសាធារណៈ

គេប្រកាសថាវាជាគោលនយោបាយសាធារណៈរបស់រដ្ឋនេះដែលចែងថា ផលប្រយោជន៍របស់និវាសនជនម្នាក់ត្រូវបាន

ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

ការពារដោយសេចក្តីថ្លែងការណ៍ពីច្បាប់សិទ្ធិមូលដ្ឋានរបស់អ្នកជំងឺ
ដែលរួមបញ្ចូលប៉ុន្តែមិនកំណត់ចំពោះសិទ្ធិដូចដែលបានបញ្ជាក់នៅក្នុងផ្នែកនេះ។

# 1. ព័ត៍មានអំពីសិទ្ធិ

យោងតាមការអនុញ្ញាត
និវាសនជនត្រូវបានប្រាប់ថាមានសិទ្ធិស្របច្បាប់សម្រាប់ការការពារខ្លួនក្នុងអំឡុងពេលការស្នាក់នៅមណ្ឌលសេវាថែទាំ
ឬមន្ទីរសេវាថែទាំអំឡុងពេលព្យាបាលនិងថែទាំនៅក្នុងសហគមន៍ហើយសិទ្ធិទាំងនេះត្រូវបានរៀបរាប់នៅក្នុងសេចក្តីថ្លែងការណ៍អមជាលាយលក្ខណ៍អក្សរអំពីសិទ្ធិ
និងតួនាទីចូលជាធរមានដូចដែលចែងក្នុងផ្នែកនេះ។ការស្នាក់នៅសមរម្យត្រូវបានផ្តល់ជូនបុគ្គលដែលអសមត្ថភាពក្នុងការប្រាស្រ័យទាក់ទង

និងបុគ្គលដែលនិយាយភាសាផ្សេងក្រៅពីអង់គ្លេស។គោលនយោបាយបច្ចុប្បន្នរបស់មណ្ឌលលទ្ធផលរកឃើញនៃការត្រួតពិនិត្យរបស់អាជ្ញាធរសុខាបាលរដ្ឋនិងមូលដ្ឋាននិងការពន្យល់បន្ថែមពីសេចក្តីថ្លែងការណ៍អំពីសិទ្ធិជាលាយលក្ខណ៍ត្រូវមានសម្រាប់និវាសនជនអាណាព្យាបាលឬអ្នកតំណាងរបស់ពួកគាត់ដែលបានជ្រើសរើសតាមការស្នើសុំសមរម្យទៅកាន់អ្នកគ្រប់គ្រងឬបុគ្គលិកផ្សេងទៀតដែលបានជ្រើសតាំងស្របជាមួយនឹងលក្ខន្តិកៈរដ្ឋ Minnesotaជំពូកទី13ច្បាប់ស្តីពីការអនុវត្តទិន្នន័យនិងមាត្រាទី626.557ទាក់ទងទៅនឹងមនុស្សពេញវ័យដែលងាយរងគ្រោះ។

## 2. ការប្រព្រឹត្តដោយសុវជីវធម៌

និវាសនជនមានសិទ្ធិទទួលបានការប្រព្រឹត្តដោយសុវជីធម៌

ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

និងកការគោរពចំពោះឯកត្តបុគ្គលភាពរបស់ខ្លួនដោ
យបុគ្គលិក
ឬអ្នកដែលផ្តល់សេវានៅក្នុងមណ្ឌលសេវាថែទាំឬមន្ទីរសេវាថែទាំ។

# 3. ការថែទាំសុខភាពសមរម្យ

និវាសនជនមានសិទ្ធិទទួលបានការថែទាំវេជ្ជសាស្ត្រនិងការថែទាំផ្ទាល់ខ្លួនអាស្រ័យលើតម្រូវការរបស់បុគ្គល។ការថែទាំសមរម្យសម្រាប់និវេសនជនមានន័យថាការថែទាំត្រូវបានផ្តល់ជូនដើម្បីអនុញ្ញាតឱ្យនិវាសនជនទទួលបាននូវសុខភាពផ្លូវកាយ
និងផ្លូវចិត្តល្អបំផុត។សិទ្ធិនេះមានកំណត់ក្នុងករណីសេវាកម្មនេះមិនអាចទូទាត់ដោយធនធានសាធារណៈឬឯកជន។

## 4. អត្តសញ្ញាណគ្រូពេទ្យ

និវាសនជនត្រូវមានឬត្រូវបានផ្តល់ជូនជាលាយលក្ខណ៍អក្សរនូវឈ្មោះអាសយដ្ឋានអាជីវកម្ម លេខទូរស័ព្ទ និងជំនាញប្រសិនបើមាន របស់គ្រូពេទ្យទទួលខុសត្រូវសម្របសម្រួលការថែទាំពួកគាត់។ក្នុងករណីមិនគួរផ្តល់សេវាពេទ្យដូចដែលបញ្ជាក់ដោយគ្រូពេទ្យប្រចាំការនៅក្នុងកំណត់ត្រាថែទាំរបស់និវាសនជនព័ត៌មានត្រូវបានផ្តល់ទៅឱ្យអាណាព្យាបាលរបស់និវាសនជនឬបុគ្គលផ្សេងទៀតដែលបានកំណត់ដោយនិវាសនជនជាតំណាងរបស់ខ្លួន។

## 5. ទំនាក់ទំនងជាមួយសេវាសុខភាពផ្សេងទៀត

និវាសនជនដែលទទួលសេវាពីអ្នកផ្តល់សេវាខាងក្រៅមានសិទ្ធិទទួលបានការជូនដំណឹងអំពីអត្ត

# ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

សញ្ញាណរបស់អ្នកផ្តល់សេវាតាមការស្នើនិវាសនជននឹងត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីសេវាថែទាំសុខភាពណាមួយដែលត្រូវបានផ្តល់ទៅឱ្យនិវាសនជនទាំងនោះដោយបុគ្គល
ក្រុមហ៊ុន
ឬអង្គភាពផ្សេងទៀតក្រៅពីមណ្ឌលរបស់ពួកគាត់។ព័ត៌មានត្រូវរួមបញ្ចូលឈ្មោះរបស់អ្នកផ្តល់សេវាកម្មខាងក្រៅ អាសយដ្ឋាន
និងការរៀបរាប់ពីសេវាដែលអាចផ្តល់ជូន។ក្នុងករណីមិនគួរផ្តល់សេវាពេទ្យដូចដែលបញ្ជាក់ដោយគ្រូពេទ្យប្រចាំការនៅក្នុងកំណត់ត្រាថែទាំរបស់និវាសនជនព័ត៌មានត្រូវបានផ្តល់ទៅឱ្យអាណាព្យាបាលរបស់និវាសនជន
ឬបុគ្គលផ្សេងទៀតដែលបានកំណត់ដោយនិវាសនជនជាតំណាងរបស់ខ្លួន។

# 6. អំពីការព្យាបាល

និវាសនជននឹងត្រូវបានផ្តល់ជូនដោយគ្រូពេទ្យនូវព័ត៌មានពេញលេញនិងបច្ចុប្បន្នដែលពាក់ព័ន្ធនឹងការធ្វើរោគវិនិច្ឆ័យ ការព្យាបាល ជម្រើសហានិភ័យនិងការព្យាករណ៍ដូចដែលតម្រូវដោយកាតព្វកិច្ចផ្លូវច្បាប់របស់គ្រូពេទ្យដើម្បីលាតត្រដាង។ព័ត៌មាននេះត្រូវមានវាក្យស័ព្ទនិងភាសាដែលនិវាសនជនត្រូវបានរំពឹងថាអាចយល់បានត្រឹមត្រូវ។និវេសនជនអាចអមជាមួយសមាជិកក្រុមគ្រួសារឬតំណាងផ្សេងទៀតដែលបានជ្រើសរើស ឬទាំងពីរ។ព័ត៌មាននេះត្រូវរួមបញ្ចូលទាំងលទ្ធផលចម្បងផ្នែកវេជ្ជសាស្ត្រឬផ្លូវចិត្តនៃការព្យាបាលនិងជម្រើស។ក្នុងករណីមិនគួរផ្តល់សេវាពេទ្យដូចដែលបញ្ជាក់ដោយគ្រូពេទ្យប្រចាំការនៅក្នុងកំណត់ត្រាថែទាំរបស់និវាសនជនព័ត៌មានត្រូវបានផ្តល់ទៅឱ្យអាណាព្យាបាលរបស់និវាសនជន

# ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

ឬបុគ្គលផ្សេងទៀតដែលបានកំណត់ដោយនិវាសនជនជាតំណាងរបស់ខ្លួន។បុគ្គលមានសិទ្ធិក្នុងការបដិសេធព័ត៌មាននេះ។

មុនពេលឬនៅពេលអនុញ្ញាតចូល និងក្នុងអំឡុងពេលស្នាក់នៅនិវាសនជនគ្រប់រូបដែលទទួលរងពីជំងឺមហារីកសុដន់ប្រភេទណាមួយត្រូវបានជូនដំណឹងឱ្យបានពេញលេញអំពីវិធីព្យាបាលទាំងអស់ដែលមានប្រសិទ្ធភាពដែលគ្រូពេទ្យព្យាបាលយល់ដឹង រួមទាំងការព្យាបាលវះកាត់វិទ្យុសាស្ត្រ ឬការព្យាបាលគីមីសាស្ត្រឬការរួមបញ្ចូលការព្យាបាលនិងហានិភ័យដែលមានទំនាក់ទំនងជាមួយវិធីសាស្ត្រនីមួយទាំងនោះ។

ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

# 7. ការចូលរួមរៀបចំគម្រោងព្យាបាល ការជូនដំណឹងរបស់សមាជិកក្រុមគ្រួសារ

1. និវាសនជនត្រូវមានសិទ្ធិចូលរួមរៀបចំគម្រោងសេវាថែទាំសុខភាពរបស់ខ្លួន។សិទ្ធិនេះរួមបញ្ចូលនូវឱកាសពិភាក្សាអំពីការព្យាបាលនិងជម្រើសជាមួយអ្នកថែទាំម្នាក់ៗ ឱកាសស្នើសុំនិងចូលរួមក្នុងសន្និសីទស្តីពីសេវាថែទាំជាផ្លូវការ និងសិទ្ធិរាប់បញ្ចូលសមាជិកក្រុមគ្រួសារឬតំណាងផ្សេងទៀតដែលបានជ្រើសរើសឬទាំងពីក្នុងករណីដែលនិវាសនជនមិនអាចមានវត្តមានសមាជិកគ្រួសារឬតំណាងផ្សេងទៀតដែលបានជ្រើសរើសដោយនិវាសនជនអាចចូលរួមនៅក្នុងសន្និសីទនេះ។

# ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

2. បើនិវាសនជនដែលចូលមណ្ឌលសេវាថែទាំ ឬមន្ទីរសេវាថែទាំ សន្លប់ ឬមិនដឹងខ្លួន ឬមិនអាចទំនាក់ទំនង មណ្ឌលនេះត្រូវខិតខំប្រឹងប្រែងឲ្យបានសមស្របដូចដែលតម្រូវក្រោមកថាខ័ណ្ឌទី 3 ដើម្បីជូនដំណឹងដល់សមាជិកក្រុមគ្រួសារឬបុគ្គលណាមួយដែលបានកំណត់ជាលាយលក្ខណ៍អក្សរដោយវាសនជនជាបុគ្គលទាក់ទងក្នុងគ្រាសង្គ្រោះបន្ទាន់ និវាសនជនត្រូវបានអនុញ្ញាតចូលមណ្ឌលសេវាថែទាំ ឬមន្ទីរសេវាថែទាំ។មណ្ឌលមន្ទីរសេវាថែទាំ ឬមន្ទីរសេវាថែទាំត្រូវអនុញ្ញាតឱ្យសមាជិកគ្រួសារចូលរួមរៀបចំគម្រោងព្យាបាលក្នុងករណីមណ្ឌលនេះមិនដឹងឬគ្មានហេតុផលដើម្បីជឿថានិវាសនជនមានការបង្គាប់ជាមុនដែលមានប្រសិទ្ធភាព ឬដឹងថា

## ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

និវាសនជនបានបញ្ជាក់ជាលាយលក្ខណ៍អក្សរថា
ពួកគេមិនចង់ឲ្យសមាជិកគ្រួសារចូលរួមរៀបចំគម្រោងព្យាបាល។បន្ទាប់ពីបានជូនដំណឹងដល់សមាជិកក្រុមគ្រួសារ
ប៉ុន្តែមុនពេលដែលអនុញ្ញាតឱ្យសមាជិកក្រុមគ្រួសារចូលរួមរៀបចំគម្រោងព្យាបាលមណ្ឌលសេវាថែទាំ
ឬមន្ទីសេវាថែទាំត្រូវតែខិតខំប្រឹងប្រែងឲ្យសមស្របដោយយោងតាមការអនុវត្តវេជ្ជសាស្ត្រដើម្បីកំណត់ថាតើនិវាសនជនបានអនុវត្តការបង្គាប់ជាមុនដែលទាក់ទងទៅនឹងការសម្រេចចិត្តអំពីសេវាថែទាំសុខភាពរបស់និវាសនជន។
ចំពោះគោលបំណងនៃកថាខណ្ឌនេះ
"កិច្ចខិតខំប្រឹងប្រែងសមស្រប" រួមបញ្ចូល៖

A. ការពិនិត្យមើលផលប៉ះពាល់ផ្ទាល់ខ្លួនរបស់និវាសនជន

ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

B. ពិនិត្យមើលកំណត់ត្រាវេជ្ជសាស្ត្ររបស់និវាសនជនដែលមាននៅក្នុងមណ្ឌលនេះ

C. ការសួរលេខទំនាក់ទំនងបន្ទាន់ណាមួយ ឬសមាជិកក្រុមគ្រួសារបានទាក់ទងក្រោមមាត្រានេះ ថាតើនិវាសនជនបានអនុវត្តការបង្គាប់ជាមុនឬអត់ និងនិវាសនជនមានគ្រូពេទ្យដែលនិវាសនជនជាទូទៅទៅរកសេវាថែទាំ ហើយនិង

D. ការសួរគ្រូពេទ្យដែលជាទូទៅនិវាសនជនទៅរកសេវាថែទាំ បើដឹងថាតើនិវាសនជនបានអនុវត្តការបង្គាប់ជាមុនឬអត់។បើមណ្ឌលជូនដំណឹងដល់សមាជិកក្រុមគ្រួសារ ឬបានកំណត់លេខទំនាក់ទំនងបន្ទាន់ឬអនុញ្ញាតឱ្យសមាជិកក្រុមគ្រួសារដើម្បីចូលរួមរៀបចំគម្រោងព្យាបាលដោយយោងតាមក

ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

ថាខណ្ឌនេះ
មណ្ឌលនេះមិនទទួលខុសត្រូវចំពោះនិវាសនជនចំពោះការខូចខាតដោយមានហេតុផលថាការជូនដំណឹងរបស់សមាជិកក្រុមគ្រួសារ ឬលេខទំនាក់ទំនងបន្ទាន់ ឬការចូលរួមរបស់សមាជិកគ្រួសារគឺមិនត្រឹមត្រូវឬបានរំលោភលើសិទ្ធិឯកជនភាព។

3. ក្នុងការខិតខំប្រឹងប្រែងសមស្របដើម្បីជូនដំណឹងដល់សមាជិកក្រុមគ្រួសារឬបានកំណត់លេខទំនាក់ទំនងបន្ទាន់ មណ្ឌលសេវាថែទាំ ឬមន្ទីរសេវាថែទាំត្រូវព្យាយាមកំណត់សមាជិកគ្រួសារឬលេខទំនក់ទំនងបន្ទាន់ដែលបានកំណត់ដោយពិនិត្យមើលផលប៉ះពាល់ផ្ទាល់ខ្លួនរបស់និវេសនជន និងរបាយការណ៍វេជ្ជសាស្ត្ររបស់និវេសនជនដែលមាននៅក្នុងមណ្ឌលនេះ។បើមណ្ឌលសេវាថែទាំ

# ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

ឬមន្ទីរសេវាថែទាំមិនអាចជូនដំណឹងដល់សមាជិកគ្រួសារឬលេខទំនាក់ទំនងបន្ទាន់ក្នុងរយៈពេល 24 ម៉ោងបន្ទាប់ពីបានអនុញ្ញាតចូលមណ្ឌលសេវាថែទាំ

ឬមន្ទីរសេវាថែទាំត្រូវជូនដំណឹងដល់ទីភ្នាក់ងារសេវាសង្គមកិច្ចខោនធីទីឬភ្នាក់ងារអនុវត្តច្បាប់ក្នុងមូលដ្ឋានដែលនិវេសនជនត្រូវបានអនុញ្ញាតចូល

និងមណ្ឌលនេះមិនអាចជូនដំណឹងដល់សមាជិកក្រុមគ្រួសារឬលេខទំនាក់ទំនងបន្ទាន់ដែលបានកំណត់។ទីភ្នាក់ងារសេវាសង្គមកិច្ចខោនធីនិងទីភ្នាក់ងារអនុវត្តច្បាប់ក្នុងមូលដ្ឋានត្រូវជួយមណ្ឌលសេវាថែទាំ

ឬមន្ទីរសេវាថែទាំដើម្បីកំណត់និងជូនដំណឹងដល់សមាជិកក្រុមគ្រួសារឬលេខទំនាក់ទំនងបន្ទាន់ដែលបានកំណត់។ទីភ្នាក់ងារសេវាសង្គមខោនធីឬទីភ្នាក់ងារអនុវត្តច្បាប់ក្នុងមូលដ្ឋានដែលជួយ

ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

មណ្ឌលក្នុងការអនុវត្តមាត្រារងនេះគឺមិនទទួលខុសត្រូវចំពោះនិវាសនជនចំពោះការខូចខាតដោយមានហេតុផលថាការជូនដំណឹងរបស់សមាជិកក្រុមគ្រួសារឬលេខទំនាក់ទំនងបន្ទាន់ឬការចូលរួមរបស់សមាជិកគ្រួសារគឺមិនត្រឹមត្រូវឬរំលោភលើសិទ្ធិឯកជនរបស់អ្នកជំងឺ។

## 8. និរន្តរភាពនៃការថែទាំ

និវាសនជនត្រូវមានសិទ្ធិទទួលបានការយកចិត្តទុកដាក់យ៉ាងទៀងទាត់សមរម្យនិងប្រកបដោយនិរន្តរភាពរបស់ការងារបុគ្គលិកដរាបណាគោលនយោបាយរបស់មណ្ឌលអនុញ្ញាត។

# 9. សិទ្ធិក្នុងការបដិសេធការថែទាំ

និវាសនជនដែលមានសមត្ថភាពត្រូវមានសិទ្ធិក្នុងការបដិសេធការព្យាបាលដោយផ្អែកលើព័ត៌មានដែលតម្រូវ ក្នុងមាត្រាទី 6 ។និវាសនជនដែលមិនព្រមទទួលការព្យាបាល ការប្រើថ្នាំឬការរឹតបន្តឹងរបបអាហារនឹងត្រូវបានជូនដំណឹងអំពីលទ្ធផលចម្បងផ្នែកវេជ្ជសាស្ត្រឬផ្លូវចិត្តនៃការបដិសេធដោយមានឯកសារក្នុងកំណត់ត្រាវេជ្ជសាស្ត្ររបស់បុគ្គល។ក្នុងករណីដែលនិវាសនជនគ្មានសមត្ថភាពយល់ដឹងពីកាលៈទេសៈនោះទេ ប៉ុន្តែមិនត្រូវបានវិនិច្ឆ័យថាអសមត្ថភាពឬនៅពេលដែលលក្ខខណ្ឌច្បាប់ដាក់កម្រិតលើសិទ្ធិក្នុងការបដិសេធការព្យាបាលស្ថានភាពនិងកាលៈទេសៈនឹងត្រូវបានចងក្រងជាឯកសារយ៉ាងពេញលេញដោយគ្រូពេទ្យប្រចាំក្នុងកំណត់ត្រាវេជ្ជសាស្ត្ររបស់និវាសនជន។

ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

## 10. ការស្រាវជ្រាវពិសោធន៍

ការព្រមព្រៀងជាលាយលក្ខណ៍អក្សរដោយមានការជូនដំណឹងត្រូវបានទទួលមុនពេលការចូលរួមរបស់និវាសនជនក្នុងការស្រាវជ្រាវពិសោធន៍។ និវាសនជនមានសិទ្ធិក្នុងការបដិសេធការចូលរួម។ទាំងការយល់ព្រមនិងការបដិសេធនឹងត្រូវបានចងក្រងជាឯកសារក្នុងកំណត់ត្រាការថែទាំរបស់បុគ្គល។

## 11. សេរីភាពរួចផុតពីការធ្វើទុក្ខបុកម្នេញ

និវាសនជនត្រូវមានសេរីភាពរួចផុតពីការធ្វើទុក្ខបុកម្នេញដូចបានកំណត់ក្នុងច្បាប់ស្តីពីការការពារមនុស្សពេញ
វ័យដែលងាយរងគ្រោះ។“ការធ្វើទុក្ខបុកម្នេញ" មានន័យថាការប្រព្រឹត្តដែលបានរៀបរាប់ក្នុង

# ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

មាត្រាទី 626.5572 មាត្រារងទី 15 ឬការបង្កការឈឺចាប់ ឬរបួសលើរាងកាយដោយចេតនានិងមិនមែនជាការព្យាបាល ឬសកម្មភាពប្រព្រឹត្តដែលមានគោលបំណងបង្កើតទុក្ខព្រួយផ្លូវចិត្តឬផ្លូវអារម្មណ៍។និវាសនជនគ្រប់រូបក៏ត្រូវរួចផុតពីការគ្រប់គ្រងរាងកាយនិងគីមីដែលមិនមែនជាការព្យាបាលទេលើកលែងតែក្នុងគ្រាអាសន្នយោងតាមការចងក្រងជាឯកសារយ៉ាងពេញលេញឬបានអនុញ្ញាតជាលាយលក្ខណ៍អក្សរបន្ទាប់ពីបានពិនិត្យដោយគ្រូពេទ្យរបស់និវាសនជនសម្រាប់រយៈពេលជាក់លាក់ និងមានកំណត់ ហើយនិងតែនៅពេលដែលចាំបាច់ដើម្បីការពារនិវាសនជនពីការរងរបួសខ្លួន ឬរបួសដល់អ្នកដទៃ។.

ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

# 12. សិទ្ធិឯកជនចំពោះការព្យាបាល

និវាសនជនត្រូវមានសិទ្ធិទទួលបានការគោរព និងភាពឯកជនដោយសារវាទាក់ទងទៅនឹងកម្មវិធីថែទាំវេជ្ជសាស្ត្រនិងកម្មវិធីថែទាំផ្ទាល់ខ្លួនរបស់ពួកគាត់។ការពិភាក្សាករណី ការពិគ្រោះយោបល់ ការពិនិត្យនិងការព្យាបាលគឺជាការសម្ងាត់ហើយនឹងត្រូវធ្វើឡើងយ៉ាងយកចិត្តទុកដាក់។ភាពឯកជនត្រូវបានគោរពក្នុងអំឡុងពេលសម្អិតសម្អាងខ្លួន ងូតទឹក និងសកម្មភាពអនាម័យខ្លួនផ្សេងទៀតលើកលែងតែក្នុងករណីចាំបាច់សម្រាប់សុវត្ថិភាពឬជំនួយរបស់និវាសនជន។

# 13. ការរក្សាការសម្ងាត់នៃកំណត់ត្រា

និវាសនជនត្រូវបានធានាការសម្ងាត់នៃការកត់ត្រាពេទ្យ និងផ្ទាល់ខ្លួនរបស់ពួកគាត់ និងអាចយល់ព្រមឬបដិសេធការផ្សព្វផ្សាយទៅបុគ្គលណាមួយនៅខាងក្រៅមណ្ឌល។និវាសនជននឹងត្រូវបានជូនដំណឹងនៅពេលដែលកំណត់ត្រាផ្ទាល់ខ្លួនត្រូវបានស្នើដោយបុគ្គលណាមួយនៅក្រៅមណ្ឌល ហើយអាចជ្រើសរើសនរណាម្នាក់រួមដំណើរជាមួយពួកគាត់នៅពេលកំណត់ត្រាឬព័ត៌មានគឺជាប្រធានបទនៃការសម្ភាសន៍ផ្ទាល់ខ្លួន។ច្បាប់ចម្លងនៃកំណត់ត្រានិងព័ត៌មានជាលាយលក្ខណ៍អក្សរពីកំណត់ត្រាត្រូវបានធ្វើឡើងដោយអនុលោមតាមសិទ្ធិនេះនិងច្បាប់ស្តីពីកំណត់ត្រាសុខាភិបាលរដ្ឋ Minnesotaមាត្រាទី144.291 ដល់144.298។សិទ្ធិនេះមិនអនុវត្តចំពោះការស៊ើបអង្កេត

ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

និងការត្រួតពិនិត្យពាក្យបណ្ដឹងដោយក្រសួងសុខាភិបាលក្នុងករណីតម្រូវដោយកិច្ចសន្យាទូទាត់ដោយភាគីទីបី
ឬក្នុងករណីចែងផ្សេងពីដោយច្បាប់។

# 14. ការបង្ហាញពីសេវាដែលមាន

មុនពេលឬក្នុងពេលអនុញ្ញាតចូលនិងអំឡុងពេលស្នាក់និវាសនជននឹងត្រូវបានជូនដំណឹងអំពីសេវាដែលរាប់បញ្ចូលនៅក្នុងថ្លៃសេវាប្រចាំថ្ងៃ
ឬអត្រាថ្លៃបន្ទប់ប្រចាំថ្ងៃរបស់មណ្ឌលហើយនិងសេវាកម្មផ្សេងទៀតមានការផ្ដល់ជូនសម្រាប់គិតថ្លៃសេវាបន្ថែម។មណ្ឌលត្រូវខិតខំប្រឹងប្រែងយ៉ាងណាដើម្បីជួយដល់និវាសនជនទទួលបានព័ត៍មានទាក់ទិននឹងថាតើកម្មវិធីជំនួយវេជ្ជសាស្ត្រ Medicare ឬ Medical

ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

ត្រូវបង់ថ្លៃសេវាណាមួយ ឬទាំងអស់ដូចដែលបានជម្រាបពីខាងដើម។

## 15. សេវាឆ្លើយតប

និវាសនជនត្រូវមានសិទ្ធិទទួលបានការឆ្លើយតបភ្លាម និងសមហេតុផលទៅនឹងសំណួរនិងសំណើរបស់ពួកគាត់។

## 16. សិទ្ធិឯកជនផ្ទាល់ខ្លួន

និវាសនជនត្រូវមានសិទ្ធិទទួលបានការពិចារណាពីសិទ្ធិឯកជនភាព ឯកត្តបុគ្គលភាព និងអត្តសញ្ញាណវប្បធម៌របស់ពួកគាត់ដែលទាក់ទងទៅនឹងសុខុមាលភាពសង្គម សាសនានិងផ្លូវចិត្ត។បុគ្គលិកមណ្ឌលត្រូវគោរពសិទ្ធិឯកជននៅក្នុងបន្ទប់របស់និវាសនជនដោ

ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

យកោះទ្វាររបស់ពួកគាត់ និងស្វែងរកការយល់ព្រមមុនពេលចូលលើកលែងតែក្នុងគ្រាអាសន្ន ឬក្នុងករណីមិនគួរផ្សេង។.

## 17. បណ្តឹងសារទុក្ខ

និវាសនជនត្រូវបានលើកទឹកចិត្តនិងជួយក្នុងអំឡុងពេលស្នាក់នៅក្នុងមណ្ឌល ឬអំឡុងពេលព្យាបាលដើម្បីស្វែងយល់និងអនុវត្តសិទ្ធិរបស់ពួកគាត់ក្នុងនាមជានិវាសនជននិងពលរដ្ឋ។និវាសនជនអាចតវ៉ានិងផ្តល់អនុសាសន៍ពីការផ្លាស់ប្តូរគោលនយោបាយនិងសេវាកម្មដល់បុគ្គលិកមណ្ឌល និងអ្នកផ្សេងទៀតតាមជម្រើសរបស់ពួកគាត់ មានសេរីភាពរួចផុតពីការរាំងស្ទះ ការជ្រៀតជ្រែក ការបង្ខិតបង្ខំ ការរើសអើងឬការសងសឹកក្នុងនោះមានទាំងការគំរាមកំហែងនៃការបណ្តេញចេញ។សេចក្តីជូ

# ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

នដំណឹងអំពីនីតិវិធីបណ្តឹងសារទុក្ខរបស់មណ្ឌល ឬកម្មវិធីព្រមទាំងអាសយដ្ឋាននិងលេខទូរស័ព្ទសម្រាប់ការិយាល័យពាក្យបណ្តឹងរបស់គ្រឹះស្ថានសុខាភិបាល
និងមន្ត្រីដោះស្រាយពាក្យបណ្តឹងអនុលោមតាមច្បាប់ស្តីពីជនជាតិអាមេរិកវ័យចំណាស់
មាត្រា307(a)(12)
នឹងត្រូវបានបិទនៅក្នុងកន្លែងដែលអាចមើលឃើញ ។

រាល់មណ្ឌលសេវាថែទាំទូទៅ
និងរាល់មណ្ឌលដែលមានបុគ្គលិកច្រើនជាងពីរនាក់ដែលផ្តល់នូវសេវាសុខភាពផ្លូវចិត្តសម្រាប់អ្នកជំងឺក្រៅមន្ទីរពេទ្យត្រូវមាននីតិវិធីបណ្តឹងសារទុក្ខផ្ទៃក្នុងជាលាយលក្ខណ៍អក្សរ
យ៉ាងហោចណាស់ចែងពីដំណើរការដែលត្រូវអនុវត្ត
ការកំណត់ពេលវេលារួមមានការកំណត់ពេលវេ

ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

លាសម្រាប់ការឆ្លើយតបរបស់មណ្ឌល ផ្តល់ជូននិវាសនជននូវជំនួយនៃការតស៊ូមតិតម្រូវឱ្យមានការឆ្លើយតបជាលាយលក្ខណ៍អក្សរទៅបណ្តឹងសារទុក្ខជាលាយលក្ខណ៍អក្សរ ហើយផ្តល់ឱ្យមានការសម្រេចចិត្តទាន់ពេលវេលា ដោយអ្នកធ្វើការសម្រេចចិត្តដោយឥតលំអៀង ប្រសិនបើបណ្តឹងសារទុក្ខនេះមិនត្រូវបានដោះស្រាយ។

## 18. សិទ្ធិឯកជនចំពោះការប្រាស្រ័យទំនាក់ទំនង

និវាសនជនអាចភ្ជាប់ទំនាក់ទំនង និងប្រាស្រ័យទាក់ទងជាលក្ខណៈឯកជនជាមួយបុគ្គលដែលខ្លួនជ្រើសរើស និងចូល និងចេញពីមណ្ឌលតាមពួកគាត់ជ្រើសរើសលើកលែងករណីមានចែងដោយច្បាប់រដ្ឋ Minnesotaស្តីពីការប្តេជ្ញាចិត្ត។និវាសនជនត្រូវ

# ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

មានសិទ្ធិប្រើប្រាស់សម្ភារៈសម្រាប់សរសេរសម្ភារៈការិយាល័យនិងការផ្ញើតាមប្រៃសណីយ៍ ដែលជាបន្ទុកចំណាយរបស់ពួកគាត់។សំបុត្រផ្ទាល់ខ្លួននឹងត្រូវបានផ្ញើដោយគ្មានការជ្រៀតជ្រែកនិងទទួលបានដោយបិទស្រោមជិតក្នុងករណីមិនជំទាស់ដោយវេជ្ជសាស្ត្រ ឬកម្មវិធី និងបានចងក្រងជាឯកសារដោយគ្រូពេទ្យនៅក្នុងកំណត់ត្រាវេជ្ជសាស្ត្រ។ត្រូវមានសិទ្ធិប្រើប្រាស់ទូរស័ព្ទដែលនិវេសជនអាចធ្វើការហៅទូរស័ព្ទ និងទទួលការហៅទូរស័ព្ទព្រមទាំងនិយាយជាលក្ខណៈឯកជន។មណ្ឌលដែលមិនអាចផ្តល់នូវតំបន់ឯកជនមួយ ត្រូវធ្វើការរៀបចំសមស្របដើម្បីផ្តល់នូវឯកជនភាពនៃការហៅទូរស័ព្ទរបស់និវាសនជន។ នៅពេលអនុញ្ញាតចូលមណ្ឌលក្នុងករណីច្បាប់សហព័ន្ធហាមឃាត់ការបង្ហាញដោយគ្មានការអនុញ្ញាតនូវព័ត៌មានកំណត់អត្តសញ្ញាណនិវាសនជនទៅដល់អ្នកហៅចូលនិងភ្ញៀវនិវាសនជនឬអា

# ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

ណាព្យាបាលស្របច្បាប់ឬអ្នកអភិរក្សរបស់និវាសនជននឹងត្រូវបានផ្តល់ឱកាសក្នុងការផ្តល់សិទ្ធិអនុញ្ញាតការបង្ហាញវត្តមានរបស់និវាសនជនក្នុងមណ្ឌលទៅកាន់អ្នកហៅចូលនិងភ្ញៀវដែលអាចព្យាយាមទាក់ទងជាមួយនិវាសនជននេះ។បើអាចធ្វើបាន
អាណាព្យាបាលស្របច្បាប់ឬអ្នកអភិរក្សរបស់និវាសនជនត្រូវពិចារណាពីទស្សនៈរបស់និវាសនជនទាក់ទងនឹងការបង្ហាញវត្តមានរបស់និវាសនជននៅក្នុងមណ្ឌលសិទ្ធិនេះមានការកំណត់ក្នុងករណីដែលមិនគួរតាមវេជ្ជសាស្ត្រ
ដូចដែលបានចងក្រងជាឯកសារដោយគ្រូពេទ្យប្រចាំការនៅក្នុងកំណត់ត្រាថែទាំរបស់និវាសនជន។ក្នុងករណីត្រូវបានកំណត់ក្នុងកម្មវិធីដោយមណ្ឌល
អនុវត្តខុសផែនការបង្ការដោយអនុលោមតាមមាត្រាទី 626.557មាត្រារង 14កថាខណ្ឌ (ខ) សិទ្ធិនេះក៏ត្រូវបានកំណត់ទៅតាមនោះដែរ។

## 19. ទ្រព្យសម្បត្តិផ្ទាល់ខ្លួន

និវាសនជនអាចរក្សាទុកនិងប្រើប្រាស់សម្លៀកបំពាក់និងទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ពួកគាត់ប្រសិនជាមានកន្លែងទំនេរ លុះត្រាតែការធ្វើដូច្នេះរំលោភទៅលើសិទ្ធិរបស់និវាសនជនផ្សេងទៀតនិងលុះត្រាតែមានការប្រឆាំងផ្នែកវេជ្ជសាស្ត្រ ឬកម្មវិធី សម្រាប់មូលហេតុវេជ្ជសាស្ត្រ សុវត្ថិភាព ឬកម្មវិធីដែលបានចងក្រងជាឯកសារ។មណ្ឌលត្រូវរក្សាទុកកន្លែងទុកដាក់ដោយចាក់សោរឬផ្តល់នូវកន្លែងទុកដាក់ផ្ទាល់ខ្លួនដោយចាក់សោនៅក្នុងនោះនិវាសនជនអាចរក្សាទុករបស់មានតម្លៃរបស់ខ្លួន។មណ្ឌលអាចប៉ុន្តែមិនតម្រូវឱ្យផ្តល់សំណងឬផ្លាស់ប្តូរថ្មីនូវរបស់ដែលបាត់ឬចោរលួច។

ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

## 20. សេវាកម្មសម្រាប់មណ្ឌល

និវាសនជនមិនត្រូវអនុវត្តការងារឬសេវាកម្មសម្រាប់មណ្ឌលលុះត្រាតែសកម្មភាពនោះត្រូវបានដាក់បញ្ចូលសម្រាប់គោលបំណងព្យាបាលនិងពាក់ព័ន្ធនឹងគោលដៅសមស្របនៅក្នុងកំណត់ត្រាវេជ្ជសាស្ត្របុគ្គលរបស់ពួកគាត់ ។

## 21. ការជ្រើសរើសអ្នកផ្គត់ផ្គង់

និវាសនជនអាចទិញឬជួលទំនិញឬសេវាកម្មដែលមិនត្រូវបានរាប់បញ្ចូលនៅក្នុងអត្រាថ្លៃសេវាប្រចាំថ្ងៃពីអ្នកផ្គត់ផ្គង់តាមជម្រើសរបស់ពួកគាត់លុះត្រាតែមានការចែងផ្សេងពីនេះដោយច្បាប់។អ្នកផ្គត់ផ្គង់ត្រូវធានាថា ទំនិញទាំងនេះគឺគ្រប់គ្រាន់ដើម្បីបំពេញតម្រូវការវេជ្ជសាស្ត្រឬការព្យាបាលរបស់និវាសនជន។

ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

## 22. កិច្ចការហិរញ្ញវត្ថុ

និវាសនជនដែលមានសមត្ថភាពអាចចាត់ចែងកិច្ចការហិរញ្ញវត្ថុផ្ទាល់ខ្លួនរបស់ពួកគាត់ឬនឹងត្រូវបានផ្តល់យ៉ាងហោចណាស់នូវគណនេយ្យប្រចាំត្រីមាសនៃប្រតិបត្តិការហិរញ្ញវត្ថុតាងនាមឲ្យពួកគាត់ប្រសិនបើពួកគាត់ផ្ទេរត្ថនាទីនេះដោយអនុលោមតាមច្បាប់នៃរដ្ឋ Minnesotaទៅឱ្យមណ្ឌលនេះសម្រាប់រយៈពេលណាមួយ។

## 23. សិទ្ធិក្នុងការចូលរួម

1. និវាសនជនអាចជួបជាមួយនិងទទួលភ្ញៀវនិងចូលរួមក្នុងសកម្មភាពពាណិជ្ជកម្មសាសនានយោបាយ, ដូចដែលបានកំណត់ក្នុងមាត្រាទី 203B.11និងក្រុមសហគមន៍ដោយគ្មានការ

# ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

ជ្រៀតជ្រែកតាមឆន្ទានុសិទ្ធិរបស់ពួកគាត់ប្រសិនបើសកម្មភាពមិនបានរំលោភលើសិទ្ធិឯកជនរបស់និវាសនជនផ្សេងទៀតឬមិនត្រូវបានប្រឆាំងក្នុងកម្មវិធី។នេះរួមបញ្ចូលទាំង៖

A. សិទ្ធិក្នុងការចូលរួមជាមួយបុគ្គលផ្សេងទៀតនៅក្នុងនិងក្រៅមណ្ឌលនេះដើម្បីធ្វើការកែលម្អការថែទាំរយៈពេលវែង

B. ។សិទ្ធិក្នុងការទទួលការទស្សនកិច្ចដោយបុគ្គលណាមួយនិវាសនជន
បានតែងតាំងភ្នាក់ងារ ថែទាំសុខភាព
របស់និវាសនជន នៅក្រោមជំពូក 145C
ហើយនិង

C. សិទ្ធិក្នុងការទទួលការទស្សនកិច្ចនិងការសម្រេចចិត្តលើការថែទាំសុខភាពដោយបុគ្គលដែលបានជ្រើសតាំងដោយនិវាសនជនស្ថិតក្រោមកថាខណ្ឌទី 3។

# ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

2. នៅពេលអនុញ្ញាតចូលមណ្ឌលក្នុងករណីច្បាប់សហព័ន្ធហាមឃាត់ការបង្ហាញដោយគ្មានការអនុញ្ញាតនូវព័ត៌មានកំណត់អត្តសញ្ញាណនិវាសនជនទៅដល់អ្នកហៅចូលនិងភ្ញៀវនិវាសនជនឬអាណាព្យាបាលស្របច្បាប់ឬអ្នកអភិរក្សរបស់និវាសនជននឹងត្រូវបានផ្តល់ឱកាសក្នុងការផ្តល់សិទ្ធិអនុញ្ញាតការបង្ហាញវត្តមានរបស់និវាសនជនក្នុងមណ្ឌលទៅកាន់អ្នកហៅចូលនិងភ្ញៀវដែលអាចព្យាយាមទាក់ទងជាមួយនិវាសនជននេះ។បើអាចធ្វើបាន អាណាព្យាបាលស្របច្បាប់ឬអ្នកអភិរក្សរបស់និវាសនជនត្រូវពិចារណាពីទស្សនៈរបស់និវាសនជនទាក់ទងនឹងការបង្ហាញវត្តមានរបស់និវាសនជននៅក្នុងមណ្ឌល។

3. នៅពេលអនុញ្ញាតចូលមណ្ឌលនិវាសនជនឬអាណាព្យាបាលស្របច្បាប់ឬអ្នកអភិរក្សរបស់និវាសនជនត្រូវតែត្រូវបានផ្តល់ឱ្យនូវឱកាស

# ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

ដើម្បីកំណត់បុគ្គលដែលមិនជាប់ទាក់ទងជាមួយអ្នកណាជាសាច់ញាតិរបស់និវាសនជនទាក់ទិននឹងទស្សនកិច្ច និងការធ្វើការសម្រេចចិត្តលើការថែទាំសុខភាព។ការជ្រើសតាំងនេះត្រូវតែរាប់បញ្ចូលនៅក្នុងកំណត់ត្រាសុខភាពរបស់និវាសនជន។ទាក់ទិននឹងការធ្វើការសម្រេចចិត្តលើការថែទាំសុខភាព សេចក្តីណែនាំអំពីការថែទាំសុខភាពឬការតែងតាំងភ្នាក់ងារថែទាំសុខភាពនៅក្រោមជំពូក 145C មានអាទិភាពលើការជ្រើសតាំងនេះដែលបានធ្វើឡើងក្រោមកថាខណ្ឌនេះ។បុគ្គលដែលមិនជាប់ទាក់ទងអាចត្រូវបានកំណត់ជាបុគ្គលប្រភេទនេះដោយនិវាសនជនឬដោយក្រុមគ្រួសាររបស់និវាសនជន។

# 24. ក្រុមប្រឹក្សាពិគ្រោះយោបល់

និវាសនជន និងក្រុមគ្រួសាររបស់ពួកគាត់នឹងមានសិទ្ធិរៀបចំរក្សា និងចូលរួមក្នុងក្រុមប្រឹក្សានិវាសនជន និងគ្រួសារ។មណ្ឌលនីមួយៗត្រូវផ្តល់ជំនួយនិងទីកន្លែងសម្រាប់កិច្ចប្រជុំ។កិច្ចប្រជុំក្រុមប្រឹក្សាត្រូវបានផ្តល់ឯកជនភាពជាមួយបុគ្គលិកឬភ្ញៀវដែលចូលរួមដោយការអញ្ជើញពីក្រុមប្រឹក្សាតែប៉ុណ្ណោះ។បុគ្គលិកនឹងត្រូវបានផ្តល់តួនាទីក្នុងការផ្តល់ជំនួយនេះនិងឆ្លើយតបទៅនឹងសំណើជាលាយលក្ខណ៍អក្សរ ដែលមកពីកិច្ចប្រជុំក្រុមប្រឹក្សា។ក្រុមប្រឹក្សានិវាសនជន និងគ្រួសារនឹងត្រូវបានលើកទឹកចិត្តក្នុងការផ្តល់អនុសាសន៍ទាក់ទងនឹងគោលនយោបាយរបស់មណ្ឌល។

ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

## 25. សេវាការពារនិងតស៊ូមតិ

និវាសនជនត្រូវមានសិទ្ធិទទួលបានសមស្រប នៅពេលដែលសមរម្យដើម្បីទទួលបានសេវាការពារសិទ្ធិណាមួយ និងសេវាតស៊ូមតិដើម្បីឲ្យនិវាសនជនអាចទទួលបានជំនួយក្នុងការស្វែងយល់ដឹង អនុវត្ត និងការពារសិទ្ធិដូចដែលបានរៀបរាប់នៅក្នុងមាត្រានេះ និងនៅក្នុងច្បាប់ផ្សេងទៀត ។សិទ្ធិនេះត្រូវរួមបញ្ចូលនូវឱកាសសម្រាប់ការប្រាស័យទំនាក់ទំនងឯកជនរវាងនិវាសនជន និងតំណាងរបស់សេវាការពារសិទ្ធិ ឬសេវាតស៊ូមតិ។

# ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

## ធនធាន

### ពាក្យបណ្តឹង

ចម្ងល់ ឬពាក្យបណ្តឹងទាក់ទងទៅនឹងច្បាប់សិទ្ធិមូលដ្ឋានស្តីពីការថែទាំសុខភាពសម្រាប់និវាសនជននៅមណ្ឌលរស់នៅក្រោមការគ្រប់គ្រង ឬការថែទាំដែលបានផ្តល់ជូន អាចបញ្ជូនទៅកាន់៖

**(ការិយាល័យពាក្យបណ្តឹងរបស់គ្រឹះស្ថានសុខាភិបាល)**
**OFFICE OF HEALTH FACILITY COMPLAINTS**
P.O. Box 64970
St. Paul, MN 55164-0970
(800) 369-7994 ឬ (651) 201-4201 (ម៉ែត្រូ)
គេហទំព័រ៖
http://www.health.state.mn.us/divs/fpc/ohfcinfo/contohfc.htm
អ៊ីម៉ែល៖ health.ohfc-complaints@state.mn.us

# ច្បាប់សិទ្ធិមូលដ្ឋានក្នុងការទទួលការថែទាំសុខភាពសម្រាប់និវាសនជននៅក្នុងមណ្ឌលរស់នៅក្រោមការគ្រប់គ្រង

## ការទទួលបានសេវាថែទាំឬកម្មវិធី

ចម្ងល់ទាក់ទងនឹងការទទួលបានសេវាថែទាំឬកម្មវិធីអាចបញ្ជូនទៅកាន់៖

**(ការិយាល័យរបស់មន្ត្រីដោះស្រាយពាក្យបណ្តឹងសម្រាប់ភាពពិការនៃការលូតលាស់ និងសុខភាពផ្លូវចិត្ត)**

**THE OFFICE OF OMBUDSMAN FOR MENTAL HEALTH AND DEVELOPMENTAL DISABILITIES**

121 7th Place East, Suite 420
St. Paul, MN 55101-2117
(800) 657-3506 or (651) 757-1800 (metro)
គេហទំព័រ៖ http://mn.gov/omhdd/
អ៊ីម៉ែល៖ ombudsman.mhdd@state.mn.us

Minnesota Department of Health
Licensing and Certification
PO Box 64900, St. Paul, MN 55164
651-201-4101
health.fpc-licensing@state.mn.us
www.health.mn.us

កាលបរិច្ឆេទ៖ថ្ងៃទី4 ខែធ្នូ ឆ្នាំ 2015

ដើម្បីទទួលបានព័ត៌មាននេះនៅក្នុងទម្រង់ផ្សេងៗគ្នា ហៅទូរស័ព្ទ: 651-201-4101